01154411

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 10 / 2015
ម៉ោង (Time/Heure): 13:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé: SANN RADA

E373

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រី ចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖ ការចុះលេខជាប្រភេទឯកសារ E3 ចំពោះឯកសារថ្មីៗដែលត្រូវបានទទួលយកក្នុងសំណុំរឿង ០០២/០២**

១. ក្នុងអំឡុងពេលសវនាការនៅក្នុងសំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២ ទាំងមូល ឯកសារនានាដែលបានមកក្នុងដំណាក់កាលស៊ើបសង្កេតនាពេលចុងក្រោយ ហើយបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានចុះលេខជាប្រភេទឯកសារ E3 (ឯកសារ E185 កថាខណ្ឌ ២, ៣៣ ឯកសារ E185/1 កថាខណ្ឌ ១៨ ឯកសារ E185/2 កថាខណ្ឌ ២៧ ឯកសារ E305/17)។ ប្រភេទឯកសារ E3 កត់សម្គាល់នូវឯកសារដែលបានទទួលយក ហើយអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងអាចយកមកធ្វើជាសំអាង ក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន អនុលោមតាមវិធាន៨៧(២) នៃវិធានផ្ទៃក្នុង (*សូមមើលផងដែរ* សាលក្រមក្នុងសំណុំរឿង០០២/០១ កថាខណ្ឌ ២៣, សាលក្រមក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៣៨)។

២. នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានទទួល និងសម្រេចលើសំណើជាច្រើនដែលស្នើសុំឲ្យទទួលយកឯកសារថ្មីៗអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

បន្ទាប់ពីបានដាក់ឯកសារថ្មីៗដែលបានស្នើឡើងត្រូវបានចុះលេខជាប្រភេទឯកសារ E ដូចដែលបានភ្ជាប់ទៅនឹងសំណើ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលពាក់ព័ន្ធ មុនពេលការពិនិត្យឡើងវិញ ស្របតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ នៅពេលដែលឯកសារថ្មីៗត្រូវបានទទួលយក និងដាក់នៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះអាចនឹងសំអាងលើឯកសារទាំងនោះ អនុលោមតាមវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង។ ទោះជាយ៉ាងណាក្តី កាន់តែមានការលំបាកក្នុងការស្វែងរកឯកសារថ្មីៗដែលត្រូវបានទទួលយក និងត្រូវបានបដិសេធ ដោយសារប្រភេទឯកសារថ្មីៗទាំងពីរនេះស្ថិតក្នុងប្រភេទឯកសារ E ដូចគ្នា (*សូមមើល ឧទាហរណ៍* ប្រតិចារឹកសវនាការថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ១៦)។

៣. ដើម្បីជួយសម្រួលដល់ការស្វែងរកឯកសារថ្មីៗដែលបានស្នើឡើង អង្គជំនុំជម្រះបានសម្រេចយកការអនុវត្តពីមុនរបស់ខ្លួនមកប្រើប្រាស់ជាថ្មី ដែលចុះលេខជាប្រភេទឯកសារ E3 ដល់ឯកសារថ្មីៗផងដែរ ដែលត្រូវបានទទួលយក អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E190 កថាខណ្ឌ១៨) ។ ហេតុនេះ អង្គជំនុំជម្រះសូមភ្ជាប់នូវបញ្ជីប្រភេទឯកសារ E3 សម្រាប់ឯកសារថ្មីទាំងអស់ដែលត្រូវបានទទួលយក ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ។ ទោះបីជា ភាគីអាចចូលមើលបញ្ជីពេញលេញនៃប្រភេទឯកសារ E3 នៅក្នុងបញ្ជីសម្ភារៈនៃប្រព័ន្ធ Zylab ក៏ដោយ ក៏អង្គជំនុំជម្រះនឹងបន្តធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវបញ្ជីដែលភ្ជាប់ជាមួយដែរ។